# អង្គការ សហប្រជាជាតិ

# លក្ខន្តិកៈ តុលាការ អន្តរជាតិ សំរាប់ ប្រទេស រ៉្វាន់ដា


មាត្រា១ ៖ សមត្ថកិច្ចរបស់តុលាការអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា

មាត្រា២ ៖ បទល្មើសប្រល័យពូជសាសន៍

មាត្រា៣ ៖ បទឧក្រិដ្ឋប្រឆាំងលើមនុស្សជាតិ

មាត្រា៤ ៖ ការរំលោភបំពាន មាត្រា៣ នៃអនុសញ្ញាក្រុងហ្សឺណែវនិងពិធីសារ ២ បន្ថែមលើអនុសញ្ញានេះ

មាត្រា៥ ៖ យុត្តាធិការលើបុគ្គល

មាត្រា៦ ៖ ការទទួលខុសត្រូវ របស់ឧក្រិដ្ឋជនម្នាក់ៗ

មាត្រា៧ ៖ យុត្តាធិការដែនដី និង កាលិក

មាត្រា៨ ៖ យុត្តាធិការស្របគ្នា

មាត្រា៩ ៖ អំពីការជំនុំជំរះតែមួយលើក

មាត្រា១០ ៖ ការរៀបចំ តុលាការ អន្តរជាតិ សំរាប់ ប្រទេស រ៉្វាន់ដា

មាត្រា១១ ៖ សមាសភាព សភា ជំនុំជម្រះក្តី

មាត្រា១២ ៖ លក្ខណៈសម្បត្តិ និងការជ្រើសរើសចៅក្រម

មាត្រា១២ (ស្ទួន១) ៖ ការជ្រើសរើសចៅក្រមអចិន្ត្រៃយ៍

មាត្រា១២ (ស្ទួន២) ៖ ការជ្រើសរើស និង ការតែងតាំងចៅក្រមបំរុង

មាត្រា១២ (ស្ទួន៣) ៖ ឋានៈរបស់ចៅក្រមបំរុង

មាត្រា១៣ ៖ មន្ត្រី និង សមាជិករបស់សភាជំនុំជម្រះក្តី

មាត្រា១៤ ៖ វិធាននៃនីតិវិធី និង ភស្តុតាង

មាត្រា១៥ ៖ អំពីព្រះរាជអាជ្ញា

មាត្រា១៦ ៖ អំពីការិយាល័យ ក្រឡាបញ្ជី

មាត្រា១៧ ៖ អំពីការស៊ើបអង្កេត និង ការរៀបចំដីកាចោទប្រកាន់

មាត្រា១៨ ៖ ការត្រួតពិនិត្យដីកាចោទប្រកាន់

មាត្រា១៩ ៖ ការចាប់ផ្តើម និង ការប្រព្រឹត្តទៅ នៃដំណើរការសវនាការ




រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

មាត្រា២០ ៖ សិទ្ធិជនជាប់ចោទ
មាត្រា២១ ៖ ការការពារជនរងគ្រោះ និង សាក្សី
មាត្រា២២ ៖ សាលក្រម
មាត្រា២៣ ៖ ទោសបញ្ញត្តិ
មាត្រា២៤ ៖ នីតិវិធីឧទ្ធរណ៍
មាត្រា២៥ ៖ ការពិនិត្យសេចក្ដីសំរេចឡើងវិញ
មាត្រា២៦ ៖ ការអនុវត្តសាលក្រម
មាត្រា២៧ ៖ ការលើកលែងទោស និង អនុគ្រោះទោស
មាត្រា២៨ ៖ កិច្ចសហប្រតិបត្តិការ និង ជំនួយតុលាការ
មាត្រា២៩ ៖ ឋានៈបុព្វសិទ្ធិ និង អភ័យឯកសិទ្ធិនៃតុលាការអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា
មាត្រា៣០ ៖ ការចំណាយរបស់តុលាការអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា
មាត្រា៣១ ៖ ភាសាផ្លូវការ
មាត្រា៣២ ៖ របាយការណ៍ប្រចាំឆ្នាំ


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

# លក្ខន្តិកៈតុលាការអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា
## (បានធ្វើវិសោធនកម្ម)

លក្ខន្តិកៈនេះ ត្រូវបានធ្វើវិសោធនកម្មដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ តាមការប្រទានអំណាច ក្រោមជំពូក ៧ នៃធម្មនុញ្ញរបស់អង្គការសហប្រជាតិ, តុលាការឧក្រិដ្ឋកម្មអន្តរជាតិសំរាប់កាត់ទោស ជនទាំងឡាយ ណាដែលបាន ប្រព្រឹត្តិបទល្មើសប្រល័យពូជសាសន៍ និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ មនុស្សធម៌អន្តរជាតិ ដែលបានប្រព្រឹត្តិ នៅលើទឹកដីប្រទេសរ៉្វាន់ដា និងកាត់ទោសពលរដ្ឋរ៉្វាន់ដាដែលបាន ប្រព្រឹត្តិបទល្មើសប្រល័យពូជសាសន៍ និងបទល្មើសធ្ងន់ធ្ងរផ្សេងៗទៀតដែលប្រព្រឹត្តិលើទឹកដីនៃរដ្ឋជិតខាងប្រទេសរ៉្វាន់ដា ដែលប្រព្រឹត្តិឡើងក្នុងរយៈកាលពីថ្ងៃទី ០១ ខែមករាឆ្នាំ១៩៩៤រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៤ (ចាប់ពីពេលនេះតទៅនៅក្នុង ឯកសារនេះហៅថា “តុលាការអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា”)តុលាការនេះ ត្រូវបំពេញតួនាទីដោយអនុលោម តាមបទបញ្ញតិនៃលក្ខន្តិកៈបច្ចុប្បន្ន។

### មាត្រា ១៖ សមត្ថកិច្ចរបស់តុលាការអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា

តុលាការអន្តរជាតិសំរាប់ប្ររទេសរ៉្វាន់ដា មានអំណាចវិនិច្ឆ័យទោសជនទាំងឡាយណាដែលរំលោភយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់មនុស្សធម៌អន្តរជាតិដែលបានប្រព្រឹត្តិលើទឹកដីប្រទេសរ៉្វាន់ដា និងវិនិច្ឆ័យទោសពលរដ្ឋប្រទេស រ៉្វាន់ដា ណាដែលបានល្មើសនឹងច្បាប់បញ្ញតិខាងលើ ប្រព្រឹត្តិលើទឹកដីប្រទេសជិតខាងជាមួយប្រទេសរ៉្វាន់ដា ដែលបាន ប្រព្រឹត្តិក្នុងរយៈ កាលពីថ្ងៃ ទី ០១ ខែមករាឆ្នាំ ១៩៩៤ រហូតដល់ថ្ងៃទី ៣១ ខែធ្នូឆាំ ១៩៩៤ អនុលោមតាម បញ្ញតិ នៃលក្ខន្តិកៈបច្ចុប្បន្ន។

### មាត្រា ២៖ បទល្មើសប្រល័យពូជសាសន៍

១-តុលាការអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា មានអំណាចវិនិច្ឆ័យទោសជនទាំងឡាយណាដែលប្រព្រឹត្តិបទល្មើស ប្រល័យ ពូជសាសន៍ ដូចដែលបានកំណត់នៅកថាខ័ណ្ឌ២ នៃមាត្រានេះ ឬ ប្រព្រឹត្តិអំពើណាមួយដែលបានរៀបរាប់ នៅកថាខ័ណ្ឌ ៣ នៃមាត្រានេះ ។

២-អំពើប្រល័យពូជសាសន៍មានន័យថាជាអំពើខាងក្រោម ដែលបានប្រព្រឹត្តិក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធ ឬ ពូជសាសន៍ណាមួយដូចជា:


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

(ក) ការសំលាប់ទៅលើសមាជិកនៃក្រុម

(ខ) បង្ករបួសស្នាមជាទំងន់ដល់រាងកាយ ឬ ដល់សតិបញ្ញាទៅលើសមាជិកនៃក្រុម

(គ) ការធ្វើអោយប៉ះពាល់ដោយចេតនានូវស្ថានភាពរស់នៅក្នុងក្រុមដើម្បីបំផ្លិចបំផ្លាញដល់ រាងកាយ ទាំងស្រុង ឬ មួយផ្នែក

(ឃ) ដាក់វិធានការណ៍ក្នុងបំណងទប់ស្កាត់ការផ្តល់កំណើតដល់ទារករបស់ក្រុម

(ង) ចាប់បង្ខំផ្ទេរកុមារពីក្រុមមួយទៅក្រុមមួយផ្សេងទៀត

៣-បទល្មើសដែល ត្រូវដាក់ទណ្ឌកម្មមានដូចខាងក្រោមៈ

(ក) បទប្រល័យពូជសាសន៍

(ខ) អំពើផ្សំគំនិតប្រព្រឹត្តិបទល្មើសប្រល័យពូជសាសន៍

(គ) ការញុះញង់ដោយផ្ទាល់និងជាសាធារណៈអោយប្រព្រឹត្តិបទប្រល័យពូជសាសន៍

(ឃ) ការប៉ុនប៉ងប្រព្រឹត្តិបទប្រល័យពូជសាសន៍

(ង) ការរួបរួមប្រព្រឹត្តិបទប្រល័យពូជសាសន៍

## មាត្រា ៣៖ បទឧក្រិដ្ឋប្រឆាំងលើមនុស្សជាតិ

តុលាការអន្តរជាតិសំរាប់ប្រទេសវ៉ាន់ដា មានអំណាចវិនិច្ឆ័យទោសជនទាំងឡាយណាដែលទទួលខុសត្រូវក្នុងការ ប្រព្រឹត្តិអំពើដូចខាងក្រោម ដែលបានវាយប្រហារជាទូទៅ ឬ ដោយមានការរៀបចំប្រឆាំងទៅលើ ជនស៊ីវិលដោយ មូលហេតុជាតិ នយោបាយ ជាតិពន្ធ ពូជសាសន៍ ឬ សាសនាណាមួយដូចជាៈ

(ក) មនុស្សឃាត

(ខ) ការសំលាប់បំបាត់ពូជសាសន៍

(គ) ការយកធ្វើជាទាសៈ

(ឃ) ការនិរទេស

(ង) ការដាក់គុក

(ច) ការធ្វើទារុណកម្ម


រក្សាសិទ្ធ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

(ឆ) ការរំលោភផ្លូវភេទ

(ជ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ជាតិសាសន៍ និង សាសនា

(ឈ) អំពើអមនុស្សធម៌ផ្សេងៗទៀត

## មាត្រា ៤៖ ការរំលោភបំពានមាត្រា ៣នៃអនុសញ្ញាក្រុងហ្សឺណែវ និងពិធីសារ២បន្ថែមលើអនុសញ្ញានេះ

តុលាការអន្តរជាតិសំរាប់ប្រទេសរ្វ៉ាន់ដា មានអំណោចវិនិច្ឆ័យទោសជនទាំងឡាយណាដែលបានប្រព្រឹត្ត ឬ បានបញ្ជាលើការប្រព្រឹត្តិយ៉ាងធ្ងន់ធ្ងរទៅលើមាត្រា៣នៃអនុសញ្ញាក្រុងហ្សឺណែវស្តីពីការការពារជនរងគ្រោះដោយសារសង្គ្រាម ចុះនៅថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ និងពិធីសារ២បន្ថែមលើអនុសញ្ញានេះ អនុម័តនៅ ថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ១៩៧៧ ។ បទល្មើសទាំងនេះត្រូវរួមបញ្ចូល ក៏ប៉ុន្តែមិនត្រូវកំហិតចំពោះ ៖

(ក) អំពើហឹង្សាដល់ជីវិត សុខភាព និងរាងកាយឬសុខភាពស្មារតីរបស់មនុស្សជាពិសេសអំពើ មនុស្សឃាដ ព្រមទាំងអំពើឃោរឃៅផ្សេងទៀតដូចជាការធ្វើទារុណកម្ម ការកាត់អវះយវៈ ឬការធ្វើទារុណកម្មលើ រាងកាយ មនុស្សតាមរូបភាពផ្សេងៗ

(ខ) ការចាប់មនុស្សធ្វើជាចំណាប់ខ្មាំង

(គ) អំពើភេវរកម្ម

(ឃ) ការប្រមាថលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ជាពិសេសការធ្វើអោយអាម៉ាស់ និង ការបន្ទាបបន្ថោក អំពើរំលោភផ្លូវភេទ ពេស្យាចារដោយបង្ខំ និង រាល់ទំរង់នៃការបៀតបៀនកេរ្តិ៍ខ្មាស់

(ង) អំពើលួចប្លន់

(ច) ការកាត់ទោស និងការប្រហារជីវិតដោយគ្មានការសំរេចពីតុលាការស្របច្បាប់ ការផ្តល់លទ្ធភាពលើការធានាផ្នែកតុលាការដែលត្រូវទទួលស្គាល់ថាមិនអាចចៀសបានដោយប្រជាជនដែលមានអារ្យធម៌។

(ឆ) អំពើគំរាមកំហែងអោយគេប្រព្រឹត្តិបទល្មើសនៅខាងមុខ

## មាត្រា ៥៖ យុត្តាធិការលើបុគ្គល


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

តុលាការអន្តរជាតិ សំរាប់ប្រទេសវ៉ាន់ដា មានអំណាចគ្របដណ្តប់ លើរូបវន្តបុគ្គលទាំងអស់ អនុលោមតាមបទបញ្ញាតិ នៃ លក្ខន្តិកៈបច្ចុប្បន។

## មាត្រា ៦៖ ការទទួលខុសត្រូវរបស់ឧក្រិដ្ឋជនម្នាក់ៗ

១-ជនណាដែលបានរៀបចំផែនការ ញុះញុង់ បញ្ជា ប្រព្រឹត្តិ ឬ បានជួយនិង សមគំនិត ក្នុងការរៀបចំផែនការ ការរៀបចំ ឬ ការប្រព្រឹត្តិឧក្រិដ្ឋ ដូចមានចែងក្នុង មាត្រា២ ដល់ មាត្រា៤ នៃលក្ខន្តិកៈនេះ ត្រូវទទួលខុសត្រូវរៀងៗខ្លួនចំពោះបទឧក្រិដ្ឋនោះ ។

២-ជនជាប់ចោទដែលមានតួនាទីផ្លូវការ ទោះបីជាប្រមុខរដ្ឋឬប្រមុខរដ្ឋាភិបាល ឬជាមន្ត្រីរដ្ឋាភិបាលក្តី មិនត្រូវបាន រួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ឬ ពីការបន្ធូរបន្ថយទោសឡើយ។

៣-បទល្មើសណាមួយក្នុងចំណោមបទល្មើសដែលមានចែងនៅមាត្រា២ ដល់ មាត្រា៤ នៃលក្ខន្តិកៈនេះ ដែលត្រូវ បានប្រព្រឹត្តិដោយមន្ត្រីនៅក្រោមបង្គាប់ណាម្នាក់ មិនបានធ្វើអោយថ្នាក់លើរបស់ជននោះ រួចផុតពីការ ទទួលខុសត្រូវចំពោះបទឧក្រិដ្ឋឡើយ ប្រសិនបើថ្នាក់លើនេះ បានដឹង ឬ មានហេតុផលដឹងថាមន្ត្រីនៅក្រោម បង្គាប់ បានប្រព្រឹត្តិ បទល្មើស ឬ បានប្រព្រឹត្តិ សកម្មភាពបែបនេះ ហើយខានមិនបានចាត់វិធានការណ៍ចាំបាច់និង សមស្រប ដើម្បី រារាំងអំពើបែបនេះ ឬដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋជននេះ។

៤-ជនជាប់ចោទដែលបានប្រព្រឹត្តិអំពើល្មើសតាមការបញ្ជាពីរដ្ឋាភិបាល ឬ ពីថ្នាក់លើណាមួយ មិនត្រូវ រួចផុត ពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋឡើយ ក៏ប៉ុន្តែគាត់អាចត្រូវសំរាលទោស ប្រសិនបើតុលាការ អន្តរជាតិសំរាប់ ប្រទេសវ៉ាន់ដាធ្វើការសំរេចបែបនេះ ។

## មាត្រា ៧៖ យុត្តាធិការដែនដី និង កាលិក

យុត្តាធិការរបស់តុលាការអន្តរជាតិសំរាប់វ៉ាន់ដាគ្របដណ្តប់លើដែនដីនៃអាណាចក្រវ៉ាន់ដា ទាំងមូលរួមទាំងដែនគោក និង ដែនអាកាស ព្រមទាំងដែននៃរដ្ឋជិតខាងផងដែរក្នុងរឿងបំពានច្បាប់មនុស្សធម៌អន្តរជាតិធ្ងន់ធ្ងរដែលបានប្រព្រឹត្តិដោយពលរដ្ឋវ៉ាន់ដា។ យុត្តាធិការកាលិករបស់តុលាការអន្តរជាតិជាតិសំរាប់ប្រទេសវ៉ាន់ដាមានអាណត្តិចាប់ផ្តើមពី ថ្ងៃទី១ ខែមករា ឆ្នាំ ១៩៩៤ ហើយបញ្ចប់ទៅវិញនៅថ្ងៃទី ៣១ខែធ្នូ ឆ្នាំ១៩៩៤ ។

## មាត្រា ៨៖ យុត្តាធិការស្របគ្នា


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

១-តុលាការអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា និង តុលាការជាតិប្រទេសរ៉្វាន់ដាមានយុត្តាធិការដូចគ្នាក្នុងការវិនិច្ឆ័យទោសជនទាំងឡាយណាដែលបានរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលបានប្រព្រឹត្ត លើទឹកដី រ៉្វាន់ដា និង វិនិច្ឆ័យទោសពលរដ្ឋរ៉្វាន់ដា ណាដែលបានប្រព្រឹត្តិអំពើឧក្រិដ្ឋលើទឹកដីនៃប្រទេស ជិតខាងជាប់ជាមួយ ប្រទេស រ៉្វាន់ដា ក្នុងកំឡុងថ្ងៃទី១ខែមករា ឆ្នាំ១៩៩៤ ដល់ថ្ងៃទី ៣១ខែធ្នូ ឆ្នាំ១៩៩៤ ។

២-តុលាការអន្តរជាតិសំរាប់ប្រទេសរ៉្វែនដាមានតួនាទីនាំមុខតុលាការជាតិទាំងអស់ ។រាល់តំណាក់កាលនៃនីតិវិធីតុលាការអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា អាចស្នើរសុំជាផ្លូវការទៅតុលាការជាតិផ្អាកយុត្តាធិការ ដោយអនុលោម តាមលក្ខន្តិកៈ បច្ចុប្បន និង ច្បាប់នីតិវិធី និងភស្តុតាងរបស់តុលាការអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា ។

## មាត្រា ៩៖អំពីការជំនុំជំរះតែមួយលើក

១-គ្មានជនណាម្នាក់ត្រូវបានវិនិច្ឆ័យទោសដោយតុលាការជាតិសំរាប់អំពើល្មើសយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ អនុលោមតាមបទបញ្ញាត្តិរបស់លក្ខន្តិកៈបច្ចុប្បន្ន ក្នុងករណីដែលជននោះ ត្រូវបានតុលាការអន្តរជាតិសំរាប់ ប្រទេសរ៉្វាន់ដាបានសំរេច វិនិច្ឆ័យទោសលើរូបគាត់រួចហើយ ។

២-ជនណាដែលត្រូវបានតុលាការជាតិវិនិច្ឆ័យទោសសំរាប់អំពើបំពាបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិរួចអាចត្រូវបានវិនិច្ឆ័យទោសដោយតុលាការអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដាទៀតប្រសិនបើៈ

(ក) បទល្មើសដែលជននោះត្រូវបានវិនិច្ឆ័យទោសគឺជាបទល្មើសធម្មតា ឬ

(ខ) នីតិវិធីរបស់តុលាការជាតិមានលក្ខណៈលំអៀងនិងមិនមានភាពឯករាជ្យហើយត្រូវបានរៀបចំឡើងគ្រាន់តែជាការបិទបាំងជនជាប់ចោទពីការទទួលខុសត្រូវពីបទឧក្រិដ្ឋ ឬក៏រឿងក្តីនោះមិនបានធ្វើការវិនិច្ឆ័យ ត្រឹមត្រូវ។

៣-ដោយពិចារណាអំពីទោសដែលនឹងត្រូវដាក់លើជនដែលត្រូវផ្តន្ទាទោសពីបទឧក្រិដ្ឋក្រោមបទបញ្ញាត្តិនៃលក្ខន្តិកៈ បច្ចុប្បន្ន តុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា នឹងពិចារណា អំពីទណ្ឌកម្មដែលសំរេចដោយតុលាការជាតិ លើ បុគ្គលដូចគ្នាសំរាប់អំពើ ដូចគ្នាដែលបានធ្វើការសំរេចរួចហើយ ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

## មាត្រា ១០៖ ការរៀបចំតុលាការអន្តរជាតិសំរាប់ប្រទេសរ្វ៉ាន់ដា

តុលាការអន្តរជាតិសំរាប់ប្រទេស រ្វ៉ាន់ដា មានអង្គការចាត់តាំងខាងក្រោមៈ

(ក) សភាជំនុំជម្រះក្តី ដែលមានសភាជំនុំជម្រះក្តីចំនួនបី និង សភាឧទ្ធរណ៍

(ខ) ព្រះរាជអាជ្ញា

(គ) ការិយាល័យក្រឡាបញ្ជី

## មាត្រា ១១៖ សមាសភាពសភាជំនុំជម្រះក្តី

១-សភាជំនុំជម្រះក្តីមានចៅក្រមកាត់ក្តីឯករាជ្យអចិន្ត្រៃយ៍ចំនួន ១៦រូប ។ ចៅក្រមពីររូបនេះមិនអាចជាចៅក្រម ដែលមានសញ្ជាតិនៃប្រទេសតែមួយទេ ហើយរាល់ពេលសវនាការនីមួយៗមានចៅក្រមបំរ៉ុងឯករាជ្យចំនួន៩រូប ច្រើនបំផុតដែល ត្រូវបានតែងតាំង យោងតាមមាត្រា ១២ (ស្ទួន២) កថាខ័ណ្ឌ២នៃ បទបញ្ញត្តិលក្ខន្តិកៈ បច្ចុប្បន្ន ដែល ចៅក្រម ពីររូបនេះមិនអាចជាចៅក្រម ដែលមានសញ្ជាតិនៃប្រទេសតែមួយឡើយ។

២-ចៅក្រមអចិន្ត្រៃយ៍ ៣រូប និង ចៅក្រមបំរ៉ុង៩រូប យ៉ាងច្រើនបំផុតនៅរាល់ពេលសវនាការនីមួយៗ ត្រូវជា សមាជិករបស់សភាជំនំជម្រះក្តីនីមួយៗ ។សភាជំនុំជម្រះក្តីនិមួយៗដែលក្នុងនោះចៅក្រមបំរ៉ុងដែលត្រូវចាត់តាំង អាចត្រូវបែងចែកជាក្រុម ដែលក្នុងមួយក្រុមៗមានចៅក្រមចំនួនបីរូប (ទាំងចៅក្រមអចិន្ត្រៃយ៍ និង ចៅក្រម បំរ៉ុង) ។ ក្រុមសភាជំនុំជម្រះក្តីត្រូវមានអំណាច និង ការទទួលខុសត្រូវដូចគ្នានឹងសភាជំនុំជម្រះក្តីដែរ ក្រោម បញ្ញត្តិ នៃលក្ខន្តិកៈ បច្ចុប្បន្ន ហើយក្រុមសភាជំនុំជម្រះក្តីនេះត្រូវចេញសាលក្រមដោយអនុលោមតាមបទបញ្ញត្តិតែមួយ។

៣-ចៅក្រមអចិន្ត្រៃយ៍ចំនួន ៧រូបជាសមាជិកនៃសភាឧទ្ធរណ៍ ។ សំរាប់ករណីប្តឹងឧទ្ធរណ៍នីមួយៗ សភាឧទ្ធរណ៍ ត្រូវមានចៅក្រមចំនួន ៥រូប ។

៤-បុគ្គលដែលមានបំណងកាយជាសមាជិកនៃសភាជំនុំជម្រះរបស់តុលាការអន្តរជាតិសំរាប់ប្រទេស រ្វ៉ាន់ដា ត្រូវបានចាត់ទុកថាមាន សញ្ជាតិតែមួយរបស់រដ្ឋដែលជននោះអនុវត្តសិទ្ធិស៊ីវិល និង នយោបាយ បើជននោះ មានសញ្ជាតិច្រើន។

## មាត្រា១២ ៖ លក្ខណៈសម្បត្តិនិងការជ្រើសរើសចៅក្រម


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ចៅក្រមអចិន្ត្រៃយ៍ និងចៅក្រមបំរុងត្រូវជាបុគ្គលមានសីលធម៌ខ្ពស់ មានភាពមិនលំអៀង និង សុចរិតទៀងត្រង់ដែលមានលក្ខណៈសម្បត្តិតម្រូវនៅក្នុងប្រទេសរៀងៗខ្លួនសំរាប់ការតែងតាំងជាតំណែងចៅក្រមខ្ពស់បំផុត។ នៅក្នុងសមាសភាព នៃសភាជំនុំជម្រះនិងក្រុមជំនុំជម្រះ ត្រូវមានចៅក្រមដែលមានបទពិសោធន៍ខាងច្បាប់ ព្រហ្មទណ្ឌ។

**មាត្រា ១២ (ស្ទួន១) ៖ ការជ្រើសរើសចៅក្រមអចិន្ត្រៃយ៍**

១-ចៅក្រមអចិន្ត្រៃយ៍១១រូបរបស់តុលាការអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដានឹងត្រូវបានជ្រើសរើសដោយមហាសន្និបាតអង្គការសហប្រជាជាតិ ពីបញ្ជីរាយនាមបេក្ខជនដែលដាក់ជូនដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជា ជាតិ ហើយការជ្រើសរើស នេះប្រព្រឹត្តិ ទៅដូចខាងក្រោមៈ

(ក) លោកអគ្គលេខាធិការត្រូវស្នើសុំការតែងតាំងបេក្ខភាពចៅក្រមអចិន្ត្រៃយ៍របស់តុលាការអន្តរជាតិ សំរាប់ប្រទេស រ៉្វាន់ដា ពីរដ្ឋនានាជាសមាជិកអង្គការសហប្រជាជាតិ និងរដ្ឋមិនមែនជាសមាជិកដែលរក្សាបេសកម្ម សង្កេតការណ៍អចិន្ត្រៃយ៍នៅទីស្នាក់ការកណ្តាល នៃអង្គការសហប្រជាជាតិ។

(ខ) ក្នុងរយៈពេល ៦០ថ្ងៃបន្ទាប់ពីការកោះអញ្ជើញរបស់លោកអគ្គលេខាធិការ រដ្ឋនីមួយៗ អាច តែងតាំង បេក្ខជនពីររូបដែលមានគុណសម្បត្តិដូចកំណត់នៅមាត្រា ១២ នៃលក្ខន្តិកៈបច្ចុប្បន្ន។បេក្ខជនទាំង ពីររូបនេះមិនត្រូវ មានសញ្ជាតិដូចគ្នា និង គ្មានបេក្ខជនណាម្នាក់ក្នុងចំណោមនោះមានសញ្ជាតិដូច ជាចៅក្រម ដែលជាសមាជិកនៃ សភាជំនុំជម្រះឧទ្ធរណ៍ ហើយបេក្ខជន ដែលត្រូវបានជ្រើសរើស ឬតែងតាំង ជាចៅក្រមអចិន្ត្រៃយ៍នៃតុលាការ អន្តរជាតិសំរាប់កាត់ទោសជនដែល ទទួលខុសត្រូវក្នុងការ រំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌ ប្រព្រឹត្តិនៅលើ ទឹកដីអតីតប្រទេស យូហ្គោស្លាវី ក្នុងកំឡុងឆ្នាំ ១៩៩១ (ចាប់ពីពេលនេះតទៅនៅក្នុងឯកសារនេះហៅថា "តុលាការ អន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី" យោងតាម មាត្រា ១៣ (ស្ទួន) នៃលក្ខន្តិកៈរបស់តុលាការនោះ ។

(គ) អគ្គលេខាធិការត្រូវបញ្ជូនបញ្ជីរាយនាមបេក្ខជនដែលបានទទួលតែងតាំងទៅក្រុមប្រឹក្សាសន្តិសុខ អង្គការសហប្រជាជាតិ ។ ក្រុមប្រឹក្សាសន្តិសុខ អង្គការសហប្រជាជាតិ ត្រូវបង្កើតបញ្ជីរាយនាមថ្មីដែលមានបេក្ខជន មិនអោយតិចជាង ២២នាក់ ហើយមិនអោយច្រើនជាង


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

៣៣នាក់ ដោយផ្អែកលើបញ្ជីនាមបេក្ខជនតែងតាំង ដែលបានទទួល នោះ ដោយពិចារណាលើតំណាងគ្រប់គ្រាន់ សំរាប់តុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា នៃគោលការណ៍ របស់ប្រព័ន្ធច្បាប់ពិភពលោក ។

(ឃ) ប្រធានក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិត្រូវបញ្ជូបញ្ជីរាយនាមបេក្ខជននេះទៅប្រធាន មហាសនិបាតអង្គការសហប្រជាជាតិ ។ ដោយផ្អែកលើបញ្ជីនេះ មហាសន្និបាតសហប្រជាជាតិនឹងជ្រើសរើស ចៅក្រមអចិន្ត្រៃយ៍នៃតុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ចំនួន ១១រូប។ បេក្ខជនដែលទទួលបានសំលេង បោះឆ្នោតគាំទ្រច្រើនលើសលុបពីរដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិ និងរដ្ឋមិនមែនជាសមាជិក ក៏ប៉ុន្តែមាន បេសកម្មសង្កេតការណ៍អចិន្ត្រៃយ៍នៅទីស្នាក់ការកណ្តាលអង្គការ សហប្រជាជាតិ ត្រូវប្រកាសថាបានជ្រើសតាំង ។

២-នៅពេលតំណែងចៅក្រមអចិន្ត្រៃយ៍ទុកនៅទំនេរ អនុលោមតាមមាត្រានេះ ហើយបន្ទាប់ពីបានពិគ្រោះយោបល់ ជាមួយប្រធានក្រុមប្រឹក្សាសន្តិសុខនិង មហាសន្និបាតសហអង្គការប្រជាជាតិអគ្គលេខាធិការត្រូវជ្រើសតាំងបុគ្គលណា ដែលមានគុណសម្បត្តិដូចបានកំណត់នៅមាត្រា ១២នៃលក្ខន្តិកៈបច្ចុប្បន្នសំរាប់រយៈពេលនៅសល់ ។

៣-ចៅក្រមអចិន្ត្រៃយ៍ដែលបានជ្រើសតាំងអនុលោមតាមមាត្រានេះ ត្រូវបានជ្រើសរើសសំរាប់រយៈពេល៤ឆ្នាំ ។
អាណត្តិនិងល័ក្ខខ័ណ្ឌការងារដូចគ្នានឹងចៅក្រមអចិន្ត្រៃយ៍នៃតុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោសលាវី ដែរ ។ ពួកគេអាចត្រូវជ្រើសតាំងម្តងទៀត។

## មាត្រា ១២ (ស្ទួន២) ៖ ការជ្រើសរើស និង ការតែងតាំងចៅក្រមបំរុង

១-ចៅក្រមបំរុងតុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ត្រូវជ្រើសតាំង ដោយមហាសន្និបាតអង្គការ សហប្រជាជាតិ ចេញពីបញ្ជីរាយនាមបេក្ខជនដែលដាក់ជូនដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ហើយ របៀបរបបជ្រើសតាំងប្រព្រឹត្តិទៅដូចខាងក្រោមៈ

(ក)លោកអគ្គលេខាធិការត្រូវស្នើសុំការតែងតាំងបេក្ខភាពចៅក្រមបំរុងរបស់តុលាការអន្តរជាតិសំរាប់ ប្រទេស រ៉្វាន់ដា ពីរដ្ឋនានាជាសមាជិកអង្គការសហប្រជាជាតិ និង រដ្ឋមិនមែនជា


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

សមាជិក ដែលមានបេសកម្មសង្កេតការណ៍អចិន្ត្រៃយ៍នៅទីស្នាក់ការកណ្តាលនៃអង្គការសហប្រជាជាតិ ។

(ខ) ក្នុងរយៈពេល៦០ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការស្នើសុំការតែងតាំងរបស់លោកអគ្គលេខាធិការ អង្គការសហប្រជាជាតិរដ្ឋនីមួយៗអាចតែងតាំង បេក្ខជនបានរហូតដល់ទៅ៤រូប ដែលមាន គុណសម្បត្តិដូចកំណត់ នៅ មាត្រា ១២នៃលន្តិកៈបច្ចុប្បន្ន ដោយធ្វើការពិចារណាអំពីសារៈសំខាន់នៃភាពជាតំណាងត្រឹមត្រូវនៃ បេក្ខជន ជាស្ត្រី និងបុរស ។

(គ) អគលេខាធិការ អង្គការសហប្រជាជាតិ ត្រូវបញ្ជូន បញ្ជីរាយនាម បេក្ខជនតែងតាំងទៅក្រុមប្រឹក្សា សន្តិសុខអង្គការសហប្រជាជាតិ ។ ក្រុមប្រឹក្សាសន្តិសុខ អង្គការសហប្រជាជាតិ ត្រូវបង្កើតបញ្ជីរាយនាមថ្មីដែលមាន បេក្ខជន មិនអោយតិចជាង ៣៦នាក់ ហើយមិនអោយច្រើនជាង ៣៣នាក់ ដោយផ្អែកលើបញ្ជីនាមបេក្ខជនតែងតាំង ដែលបានទទួល នោះ ដោយពិចារណាលើតំណាងគ្រប់គ្រាន់ សំរាប់តុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា នៃគោលការណ៍ របស់ប្រព័ន្ធច្បាប់ពិភពលោក និងអំពីសារៈសំខាន់នៃការបែងចែកដោយសមធម៌តាមភូមិសាស្ត្រ ។

(ឃ) ប្រធានក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិត្រូវបញ្ជូនបញ្ជីរាយនាមបេក្ខជននេះទៅប្រធានមហាសន្និបាតអង្គការសហប្រជាជាតិ។ ដោយផ្អែកលើបញ្ជីនេះ មហាសន្និបាតសហប្រជាជាតិនឹងជ្រើសរើស ចៅក្រមបំរុងនៃតុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ចំនួន១៨រូប ។ បេក្ខជនដែលទទួលបានសំលេង បោះឆ្នោត គាំទ្រច្រើនលើសលុបពីរដ្ឋជាសមាជិក នៃអង្គការសហប្រជាជាតិ និងរដ្ឋមិនមែនជាសមាជិក ក៏ប៉ុន្តែមាន បេសកម្ម សង្កេតការណ៍អចិន្ត្រៃយ៍នៅទីស្នាក់ការកណ្តាលអង្គការ សហប្រជាជាតិ ត្រូវប្រកាសថាបានជ្រើសតាំង ។

(ង) ចៅក្រមបំរុងត្រូវបានជ្រើសរើសសំរាប់រយៈពេល ៤ ឆ្នាំ ។ ពួកគេមិនអាចត្រូវជ្រើសតាំងម្តង ទៀតបានទេ។

២-ក្នុងអាណត្តិ របស់ខ្លួន ចៅក្រមបំរុង នឹងត្រូវតែងតាំងដោយ អគ្គលេខាធិការ នៃអង្គការសហប្រជាជាតិ បន្ទាប់ពី បានទទួលសំណើរបស់ប្រធានតុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ដើម្បីបំពេញតួនាទីនៅសភាជំនុំជំរះក្តី សំរាប់សវនាការមួយឬច្រើន ក្នុងរយៈពេល៣ឆ្នាំជាប់ៗគ្នា ។ នៅពេលមានការស្នើសុំតែងតាំងចៅក្រមបំរុងប្រធានតុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ត្រូវពិចារណាលើលក្ខណៈវិនិច្ឆ័យ ដែលបានកំណត់នៅ មាត្រា ១២ នៃលក្ខន្តិកៈបច្ចុប្បន្ន ។ចំពោះ


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

សមាសភាពសភាជំនុំជម្រះក្តី និងក្រុមនៃសភាជំនុំជម្រះក្តី, កត្តាដែលត្រូវបញ្ចូល ក្នុងការធ្វើវិនិច្ឆ័យដូចមានចែងនៅកថាខ័ណ្ឌ ១ (ខ) និង (គ) ហើយចំនួនសំលេងឆ្នោតគាំទ្រដែលចៅក្រម បំរុងបានទទួលពីមហាសន្និបាតអង្គការសហប្រជាជាតិ ។

## មាត្រា ១២(ស្ទួន៣)៖ ឋានៈរបស់ចៅក្រមបំរុង

១-ក្នុងពេលបំពេញភារកិច្ចជាមួយតុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ចៅក្រមបំរុងត្រូវៈ

(ក) ទទួលបានសារៈប្រយោជន៍ពី អាណត្តិ និង ល័ក្ខខ័ណ្ឌការងារបើមានការចាំបាច់ ដូចគ្នានឹង ចៅក្រម អចិន្ត្រៃយ៍របស់តុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ដែរ ។

(ខ) យោងតាមកថាខ័ណ្ឌ២ខាងក្រោម, មានអំណាចដូចគ្នានឹងចៅក្រមអចិន្ត្រៃយ៍របស់តុលាការ អន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ដែរ ។

(គ) ទទួលបាននូវបុព្វសិទ្ធិ និង អភ័យឯកសិទ្ធិ ការលើកលែង និង ឋប័នភ័ណ្ឌទាំងអស់ របស់ចៅក្រមនៃ តុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ដែរ ។

២-ក្នុងពេលបំពេញភារកិច្ចជាមួយតុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ចៅក្រមបំរុងមិនត្រូវ៖

(ក) មានសិទ្ធិឈរឈ្មោះបោះឆ្នោតជា ឬចូលរួមបោះឆ្នោតជ្រើសរើស ប្រធានតុលាការអន្តរជាតិ សំរាប់ប្រទេស រ៉្វាន់ដា ឬ ជាប្រធានសភាចៅក្រមជម្រះក្តី យោងតាមមាត្រា ១៣ នៃលក្ខន្តិកៈបច្ចុប្បន្ន។

(ខ) មានអំណាចៈ

(១) -អនុម័តវិធានទាក់ទងនឹងនីតិវិធីនិងភស្តុតាងអនុលោមតាមមាត្រា១៤ របស់លក្ខន្តិកៈបច្ចុប្បន្នក៏ប៉ុន្តែពួកគេត្រូវពិគ្រោះយោបល់សិនមុនពេលអនុម័តវិធានទាំងនោះ ។

(២) ពិនិត្យដីកាចោទប្រកាន់ យោងតាមមាត្រា ១៨នៃលក្ខន្តិកៈបច្ចុប្បន្ន

(៣) ពិគ្រោះយោបល់ជាមួយប្រធានតុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ទាក់ទងនឹងការ តែងតាំងចៅក្រម អនុលោមតាមមាត្រា ១៣ នៃលក្ខន្តិកៈបច្ចុប្បន្ន ឬទាក់ទិននឹងការលើកលែងទោស ឬបន្ថយទោស យោងតាមមាត្រា ២៧របស់លក្ខន្តិកៈបច្ចុប្បន្ន ។

(៤) ធ្វើការកាត់សេចក្តីក្នុងនីតិវិធីមុនសវនាការ ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

## មាត្រា ១៣៖ មន្ត្រី និង សមាជិករបស់សភាជំនុំជម្រះក្តី

១-ចៅក្រមចអចិន្ត្រៃយ៍នៃតុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ត្រូវជ្រើសតាំងប្រធានមួយរូបក្នុងចំណោមសមាជិកចៅក្រមទាំងអស់។

២-ប្រធានតុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ត្រូវតែជាសមាជិករបស់សភាជំនុំជម្រះមួយក្នុងចំណោមសភាជំនុំជម្រះ របស់តុលាការ ។

៣-បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយចៅក្រមអចិន្ត្រៃយ៍នៃតុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ប្រធានត្រូវ ចាត់តាំងចៅក្រមអចិន្ត្រៃយ៍ពីររូបដែលបានជ្រើសរើស ឬ តែងតាំងយោងតាមមាត្រា១២ (ស្ទួន១) នៃលក្ខន្តិកៈ បច្ចុប្បន្ន ធ្វើជាសមាជិកសភាជំនុំជម្រះក្តីនៃសាលាឧទ្ធរណ៍របស់តុលាការអន្តរជាតិសំរាប់អតីតប្រទេស យូហ្គោសាវី ហើយចាត់តាំងចៅក្រមអចិន្ត្រៃយ៍៨រូបជាសមាជិកសភាជំនុំជម្រះក្តីសំរាប់ តុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ។

៤-សមាជិកសភាជំនំជម្រះក្តីនៃសាលាឧទ្ធរណ៍របស់តុលាការអន្តរជាតិសំរាប់អតីតប្រទេស យូហ្គោស្លាវី ត្រូវធ្វើជាសមាជិកសភាជំនំជំរះក្តីនៃសាលាឧទ្ធរណ៍របស់តុលាការអន្តរជាតិសំរាប់ រ៉្វាន់ដា ដែរ ។

៥-បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយចៅក្រមអចិន្ត្រៃយ៍នៃ តុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ប្រធានត្រូវ ចាត់តាំងចៅក្រមបំរុងដែលអាចត្រូវបានតែងតាំងម្តងម្កាលអោយបំពេញភារកិច្ចនៅសភាជំនុំជម្រះក្តីរបស់តុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ។

៦-ចៅក្រមត្រូវបំពេញភារកិច្ចនៅសភាជំនុំជម្រះក្តីដែលខ្លួនត្រូវបានតែងតាំង។

៧-ចៅក្រមអចិន្ត្រៃយ៍ នៃសភាជំនុំជំម្រះក្តីនិមួយៗត្រូវជ្រើសតាំងប្រធានចៅក្រមជំរះក្តីមួយរូបក្នុងចំណោមពួកគេ ដែលត្រូវមានភារកិច្ចត្រួតពិនិត្យកិច្ចការរបស់សភាទាំងមូល ។

## មាត្រា ១៤ វិធាននៃនីតិវិធី និង ភស្តុតាង

ចៅក្រមតុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ត្រូវអនុម័តវិធាន នៃនីតិវិធី និងភស្តុតាងសំរាប់អនុវត្តន៍ដំណើរការក្តី នៃដំណាក់កាលមុនសវនាការ សវនការ និង ឧទ្ធរណ៍ ការទទួលយកភស្តុតាង ការការពារជនរងគ្រោះនិងសាក្សី និងអង្គហេតុត្រឹមត្រូវផ្សេងៗទៀតរបស់ តុលាការអន្តរជាតិសំរាប់អតីតប្រទេស យូហ្គោស្លាវី ដោយមានការ ផ្លាស់ប្តូរក្នុងករណី ចាំបាច់ សំរាប់គោលបំនងនៃដំណើរការក្តីនៅតុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

## មាត្រា ១៥៖ អំពីព្រះរាជអាជ្ញា

១-ព្រះរាជអាជ្ញាត្រូវទទួលខុសត្រូវក្នុងការស៊ើបអង្កេត និងធ្វើការចោទប្រកាន់ជនទាំងឡាយណាដែលទទួល ខុសត្រូវក្នុង ការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលបានប្រព្រឹត្តិលើទឹកដីប្រទេស រ៉្វាន់ដា និង កាត់ទោស ពលរដ្ឋ រ៉្វាន់ដា ដែលទទួលខុសត្រូវក្នុងការរំលោភយ៉ាងធ្ងន់ធ្ងរប្រព្រឹត្តលើទឹកដីនៃរដ្ឋនៅជិតខាង ជាមួយ ប្រទេស រ៉្វាន់ដា ក្នុងកំឡុងពេលចាប់ពីថ្ងៃទី ១ខែមករា ឆ្នាំ ១៩៩៤ ដល់ថ្ងៃទី ៣១ខែធ្នូ ឆ្នាំ ១៩៩៤ ។

២-ព្រះរាជអាជ្ញាត្រូវបំពេញតួនាទីដោយឯករាជ្យ ជាស្ថាប័នដាច់ដោយឡែកមួយចេញពីអង្គការតុលាការអន្តរជាតិ សំរាប់ រ៉្វាន់ដា ។ ព្រះរាជអាជ្ញាមិនត្រូវស្វែងរកឬទទួលការណែនាំបង្គាប់បញ្ជាពីរដ្ឋាភិបាល ឬពីប្រភពណាមួយឡើយ ។

៣-ព្រះរាជអាជ្ញានៃតុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី ក៏បំពេញភារកិច្ចនៅតុលាការអន្តរជាតិ សំរាប់ប្រទេស រ៉្វាន់ដា ដែរ។ គាត់ត្រូវមានបុគ្គលិកបន្ថែម រួមមានព្រះរាជអាជ្ញារងផងដែរ ដើម្បីជាជំនួយក្នុងការកាត់ទោស ចំពោះមុខតុលាការអន្តរជាតិសំរាប់ រ៉្វាន់ដា ។ បុគ្គលិកបន្ថែមទាំងនេះត្រូវបានតែងតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ដោយយោងទៅតាមអនុសាសន៍របស់ព្រះរាជអាជ្ញា។

## មាត្រា ១៦ ៖ អំពីការិយាល័យក្រឡាបញ្ជី

១-ការិយាល័យក្រឡាបញ្ជីត្រូវទទួលខុសត្រូវរាល់កិច្ចការរដ្ឋបាល និង ផ្តល់សេវាផ្សេងៗដល់តុលាការអន្តរជាតិ សំរាប់ប្រទេស រ៉្វាន់ដា ។

២-ការិយាល័យក្រឡាបញ្ជីត្រូវជំនួយដោយក្រឡាបញ្ជីកាន់កាប់បញ្ជីសំណុំរឿង និង បុគ្គលិកជំនួយការមួយចំនួនទៀត។

៣-ក្រឡាបញ្ជីកាន់កាប់បញ្ជីសំណុំរឿងត្រូវតែងតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយ ប្រធាន តុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ។គាត់មានអាណត្តិ ៤ឆ្នាំ ហើយមានសិទ្ធិតែងតាំងជាថ្មីម្តងទៀត ។ អាណត្តិ និង លក្ខខ័ណ្ឌការងាររបស់ក្រឡាបញ្ជី កាន់កាប់បញ្ជីសំណុំរឿង ដូចគ្នានឹងជំនួយការរបស់អគ្គលេខាធិការ នៃអង្គការ សហប្រជាជាតិ ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

៤-បុគ្គលិកនៃការិយាល័យក្រឡាបញ្ជីត្រូវតែងតាំងដោយលោកអគ្គលេខាធិការ យោងតាម អនុសាសន៍របស់ ក្រឡាបញ្ជីកាន់កាប់សំណុំរឿង ។

## មាត្រា ១៧៖ អំពីការស៊ើបអង្កេត និង ការរៀបចំដីកាចោទប្រកាន់

១-ព្រះរាជអាជ្ញាត្រូវផ្តួចផ្តើមការស៊ើបអង្កេតដោយអំណាចរបស់ខ្លួនផ្ទាល់ ឬ ដោយផ្អែក លើមូលដ្ឋានពត៌មានដែល ទទួលបានពីប្រភពនានា ជាពិសេសពីរដ្ឋាភិបាល ពីភ្នាក់ងារអង្គការ សហប្រជាជាតិ ពីអង្គការអន្តររដ្ឋ និងអង្គការ មិនមែនរដ្ឋាភិបាល ។ ព្រះរាជអាជ្ញាត្រូវវាយតំលៃ ពត៌មានដែលខ្លួនបានទទួល ឬទទួលបាន និង សំរេចថាតើវាមាន មូលដ្ឋានគ្រប់គ្រាន់ដើម្បីធ្វើ ចំណាត់ការបន្ត។

២-ព្រះរាជអាជ្ញាមានសិទ្ធិអំណាចសួរចំលើយជនសង្ស័យ ជនរងគ្រោះ និងសាក្សី ដើម្បី ប្រមូលភស្តុតាង និងអនុវត្តការស៊ើបអង្កេតនៅកន្លែងកើតហេតុ ។ពេលបំពេញភារកិច្ចទាំងអស់នេះ ព្រះរាជអាជ្ញាអាចស្នើសុំជំនួយពី អាជ្ញាធររដ្ឋ ដែលពាក់ព័ន្ធ ។

៣-ពេលសួរចំលើយ ជនសង្ស័យអាចទទួលបានជំនួយពីស្មារតីតាមការជ្រើសរើសរបស់ គាត់ ព្រមទាំង ទទួលបាន នូវសិទ្ធិទទួលបានជំនួយការច្បាប់ដែលគាត់មិនចាំបាច់បង់ប្រាក់ក្នុង ស្ថានការណ៍ដែលគាត់គ្មានលទ្ធភាពចំណាយ លើសេវានេះ ហើយគាត់ក៏ទទួលបាននូវជំនួយ បកប្រែភាសា ទៅជា ឬ មកជាភាសា ដែលគាត់អាចនិយាយបាន និងស្តាប់បាន ។

៤-នៅពេលធ្វើការសម្រេចចិត្តលើ រឿងក្តីមានភស្តុតាងគ្រប់គ្រាន់សំរាប់ការចោទប្រកាន់ តាមផ្លូវច្បាប់ (prima facie case) ព្រះរាជអាជ្ញាត្រូវរៀបចំដីកាចោទប្រកាន់ ដោយបង្ហាញពី អង្គហេតុច្បាស់លាស់និងបទឧក្រិដ្ឋមួយឬបទឧក្រិដ្ឋច្រើនដែលជនជាប់ចោទត្រូវទទួលការ ចោទប្រកាន់តាមលក្ខន្តិកៈនេះ ។ ដីកាចោទប្រកាន់ ត្រូវបញ្ជូនទៅ ចៅក្រមសភាជំនុំជម្រះក្តី ។

## មាត្រា ១៨ ៖ ការត្រួតពិនិត្យដីកាចោទប្រកាន់

១-ចៅក្រមសភាជំនុំជម្រះដែលមានទទួលដីកាចោទប្រកាន់ ត្រូវត្រួតពិនិត្យដីកា ចោទប្រកាន់នេះ។ ប្រសិនបើ
ចៅក្រមយល់ឃើញថា រឿងក្តីមានភស្តុតាងគ្រប់គ្រាន់សំរាប់ការចោទប្រកាន់តាមផ្លូវច្បាប់*(prima facie case)* គាត់ត្រូវបញ្ជាក់សេចក្តីយល់ព្រមលើដីកាចោទប្រកាន់នេះ ។ ប្រសិនបើចៅក្រមយល់


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ឃើញថា រឿងក្តីពុំមាន ភស្តុតាងគ្រប់គ្រាន់សំរាប់ការចោទប្រកាន់តាមផ្លូវច្បាប់ គាត់ត្រូវលើកលែងការចោទប្រកាន់ ។

២-បន្ទាប់ពីបានយល់ព្រមលើដីកាចោទប្រកាន់ហើយ តាមការស្នើសុំពីព្រះរាជអាជ្ញា ចៅក្រមអាចចេញបញ្ជា និងចេញដីកាចាប់ខ្លួន, ឃុំខ្លួន, បញ្ជាអោយចូលសារភាព, ផ្ទេរបុគ្គល ហើយចេញបញ្ជាផ្សេងៗទៀត ដែលតម្រូវ សំរាប់ ការប្រព្រឹត្តិទៅនៃសវនាការ ។

## មាត្រា ១៩ ៖ ការចាប់ផ្តើម និង ការប្រព្រឹត្តិទៅនៃដំណើរការសវនាការ

១-សភាជំនុំជម្រះត្រូវធានាថាសវនាការប្រព្រឹត្តិទៅត្រឹមត្រូវ យុត្តិធម៌ និងឆាប់រហ័ស អនុលោមតាមវិធាននៃនីតិវិធី និងភស្តុតាង ដោយមានការគោរពសិទ្ធិរបស់ជនជាប់ចោទ និងការ ការពារត្រឹមត្រូវ ដល់ជនរងគ្រោះ និង សាក្សី ។

២-ជនដែលប្រឆាំងនឹងដីកាចោទប្រកាន់ដែលបានទទួលការយល់ព្រមនេះ ដោយ អនុលោមតាមបញ្ជាឬដីកាចាប់ខ្លួន របស់តុលាការ អន្តរជាតិសំរាប់ រ៉្វាន់ដា ត្រូវបានចាប់ដាក់ពន្ធនាគារ ត្រូវបានជូនដំណឹងភ្លាមពីបទចោទប្រកាន់ ប្រឆាំងរូបគាត់ ហើយគាត់ត្រូវបានបញ្ជូន ទៅតុលាការអន្តរជាតិសំរាប់ រ៉្វាន់ដា ។

៣-ចៅក្រមសភាជំនុំជម្រះត្រូវអានដីកាចោទប្រកាន់ ប្រកាសពីការគោរពសិទ្ធិរបស់ជន ជាប់ចោទ, បញ្ជាក់ អះអាងថាជនជាប់ចោទថាជនជាប់ចោទយល់ពីបទចោទប្រកាន់ ហើយ ណែនាំជនជាប់ចោទឆ្លើយតបនឹងបទចោទ ប្រកាន់។ ចៅក្រមសភាជំនុំជម្រះត្រូវកំណត់ កាលបរិច្ឆេទសំរាប់សវនាការ ។

៤-សវនាការត្រូវធ្វើឡើងជាសាធារណៈ ល្គឹកណាចៅក្រមជំនុំជម្រះសំរេចផ្ទុយពីនេះ អនុលោមតាមវិធាននៃនីតិវិធី និងភស្តុតាង ។

## មាត្រា ២០ ៖ សិទ្ធិជនជាប់ចោទ

១-ជនគ្រប់រូបមានសិទ្ធិស្មើគ្នានៅចំពោះតុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ។

២-ក្នុងការកំណត់បទចោទប្រកាន់ប្រឆាំងលើរូបគាត់ ជនជាប់ចោទត្រូវមានសិទ្ធិទទួលបាន កាត់ទោសដោយយុត្តិធម៌ និងជាសាធារណៈ យោងតាមមាត្រា ២១នៃលក្ខន្តិកៈនេះ។

៣-ជនជាប់ចោទណាក៏ដោយត្រូវបានសន្មត់ថាគ្មានទោស ដរាបណាតុលាការមិនទាន់ កាត់ទោស អនុលោម តាមវិធាន នៃលក្ខន្តិកៈ បច្ចុប្បន្ន ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

៤-នៅក្នុងការកំណត់ការចោទប្រកាន់មកលើជនសង្ស័យ អនុលោមតាម តាមវិធាននៃលក្ខន្តិកៈបច្ចុប្បន្ន ,ជនជាប់ចោទត្រូវមានសិទ្ធិទទួល បានការធានាជាអប្បបរមា និងស្មើៗគ្នាដូចខាងក្រោម

(ក) ទទួលបានពត៌មានភ្លាមៗនិងលំអិតជាភាសាដែលខ្លួនយល់បានអំពីប្រភេទ និងមូលហេតុអំពីការចោទ ប្រកាន់ចំពោះខ្លួន។

(ខ) មានពេលវេលានិងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំខ្លួនក្នុងការការពារតតាំងជាមួយបទចោទប្រកាន់ និងទំនាក់ទំនងជាមួយស្មារតីរបស់ខ្លួន ។

(គ) ត្រូវទទួលការជំនុំជំរះដោយគ្មានការអូសបន្លាយពេលវេលា។

(ឃ) ត្រូវទទួលការជំនុំជំរះនៅពេលមានវត្តមានខ្លួនឯងឬតាមរយៈអ្នកជំនួយការច្បាប់របស់ខ្លួនដែល បាន ជ្រើសរើស ប្រសិនបើគាត់គ្មានអ្នកជំនួយការច្បាប់ គាត់ត្រូវបានជូនដំណឹងពីសិទ្ធិនេះនិង សិទ្ធិទទួលបាន អ្នកជំនួយ ការច្បាប់ នៅគ្រប់ករណីដែលជាតម្រូវការនៃយុត្តិធម៌ និងដោយមិនបាច់បង់ប្រាក់ ក្នុងករណីគាត់គ្មានលទ្ធភាព ចំណាយលើសេវានេះ ។

(ង) សួរ ឬ បានសួរសាក្សីដាក់បន្ទុកលើគាត់ ហើយទទួលបានការចូលរួម និងការសួរសាក្សីដោះបន្ទុក ក្នុងល័ក្ខខ័ណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុកដែរ ។

(ច) ទទួលបានជំនួយឧបត្ថម្ភដោយមិនគិតថ្លៃពីអ្នកបកប្រែភាសា ប្រសិនបើគាត់មិនយល់ឬមិនអាច និយាយភាសាដែលប្រើនៅតុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ។

(ឆ) មិនត្រូវបានគេបង្ខំអោយឆ្លើយប្រឆាំងនឹងខ្លួនគាត់ ឬបង្ខំអោយឆ្លើយសារភាពជាមានកំហុស។

## មាត្រា ២១ ៖ ការការពារជនរងគ្រោះ និង សាក្សី

យោងតាមវិធាននៃនីតិវិធី និងភស្តុតាង តុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ត្រូវផ្តល់ការការពារជនរងគ្រោះ និងសាក្សី ។ វិធានការការពារទាំងនោះរួមបញ្ចូលទាំងកិច្ចដំណើការសវនាការដែលធ្វើឡើងជាសាធារណៈ និងការ ការពារនូវអត្តសញ្ញាណ ជនរងគ្រោះ ប៉ុន្តែ វិធានការការពារទាំងនោះមិនត្រូវបានគេដាក់កំហិតឡើយ។

## មាត្រា ២២ ៖ សាលក្រម


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

១-សភាជំនុំជម្រះត្រូវប្រកាសសាលក្រមជាសារណៈនូវការកាត់ទោសនិងដាក់ទណ្ឌកម្មលើជនណាដែលត្រូវ
បានផ្តន្ទាទោស ក្នុងបទរំលោភច្បាប់មនុស្សធម៌អន្តរជាតិយ៉ាងធ្ងន់ធ្ងរ ។

២-សាលក្រមត្រូវសំរេចដោយសំលេងភាគច្រើននៃចៅក្រមរបស់សភាជំនុំជម្រះ និង ត្រូវថ្លែងដោយសភាចៅក្រម ជំនុំជម្រះជាសាធារណៈ។សាលក្រមត្រូវបញ្ជាក់ពីហេតុផលជាលាយល័ក្ខអក្សរ ដែលត្រូវភ្ជាប់បន្ថែមនូវ ទស្សនៈផ្ទុយ ឬខ្វែងគ្នា។

## មាត្រា ២៣ ៖ ទោសបញ្ញត្តិ

១-ទោសបញ្ញត្តិដែលសំរេចដោយសភាជំនុំជម្រះ ត្រូវកំរិតត្រឹមដាក់ពន្ធនាគារ។ ក្នុងការកំណត់រយៈពេលដាក់ពន្ធនាគារ សភាជំនុំជម្រះត្រូវមានឧបាស្រ័យចំពោះការអនុវត្តទូទៅ ទោសពន្ធនាគារ នៃតុលាការប្រទេស រ៉្វាន់ដា

២-ក្នុងការដាក់ទោសបញ្ញត្តិ សភាជំនុំជម្រះត្រូវពិចារណា នូវកត្តាជាច្រើនដូចជា ស្ថានទំងន់បទល្មើស និង កាលៈទេសៈរបស់ទន្ទិតម្នាក់ៗ ។

៣-បន្ថែមពីទោសដាក់ពន្ធនាគារ សភាជំនុំជម្រះអាចបញ្ជាអោយប្រគល់ ទ្រព្យសម្បត្តិនិងប្រាក់កាសដែលទទួលបាន ដោយ បទឧក្រិដ្ឋរួមមាន មធ្យោបាយអំពើបង្ខិតបង្ខំ ទៅម្ចាស់ស្របច្បាប់។

## មាត្រា ២៤ ៖ នីតិវិធីឧទ្ធរណ៍

១-សភាជំនុំជំម្រះឧទ្ធរណ៍ ជំនុំជម្រះបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ ឬរបស់ព្រះរាជអាជ្ញា ក្នុងល័ក្ខខ័ណ្ឌ ដូចខាងក្រោមៈ

(ក) មានការភាន់ច្រឡំលើអង្គច្បាប់ ដែលនាំអោយអសុពលភាពលើសេចក្តីសំរេច ឬ

(ខ) មានការភាន់ច្រឡំលើអង្គហេតុ ដែលនាំអោយខុសឆ្គោយរបស់តុលាការ ។

២-សភាជំនុំជម្រះសាលាឧទ្ធរណ៍អាចបញ្ជាក់ទទួលស្គាល់ បដិសេធ បពិនិត្យឡើងវិញនូវសេចក្តីសំរេចរបស់សភាជំនុំជម្រះ។

## មាត្រា ២៥ ៖ ការពិនិត្យសេចក្តីសំរេចឡើងវិញ


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ករណីដែលអង្គហេតុថ្មីដែលបានរកឃើញ ក៏មិនត្រូវបានគេដឹងនៅពេលរឿងក្តីនេះកំពុងចំណាត់ការនៅ សភាជំនុំជម្រះឬនៅសភាជំនុំជម្រះឧទ្ធរណ៍ ហើយដែលអង្គហេតុនេះគួរតែជាកត្តាឈាន ទៅរកការសំរេច, ទណ្ឌិត ឬ ព្រះរាជអាជ្ញា អាចប្តឹងឧទ្ធរណ៍ទៅតុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ពិនិត្យសេចក្តីសំរេចឡើងវិញ ។

## មាត្រា ២៦ ៖ ការអនុវត្តសាលក្រម

ការដាក់ពន្ធនាគារត្រូវធ្វើឡើងនៅប្រទេស រ៉្វាន់ដា ឬនៅរដ្ឋណាមួយក្នុងបញ្ជីឈ្មោះរដ្ឋដែលបញ្ជូនទៅក្រុមប្រឹក្សា សន្តិសុខសហប្រជាជាតិ ដែលព្រមទទួលយកទណ្ឌិត ដូចដែលបានកំណត់ដោយតុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ។ ការដាក់ពន្ធនាគារបែបនេះត្រូវអនុវត្តតាមច្បាប់ដែលកំពុងអនុវត្តនៅរដ្ឋសាម៉ី ក្រោមការត្រួតពិនិត្យដោយតុលាការអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា ។

## មាត្រា ២៧ ៖ ការលើកលែងទោស និង អនុគ្រោះទោស

អនុលោមតាមច្បាប់ដែលកំពុងអនុវត្តនៅរដ្ឋសាម៉ី ដែលទណ្ឌិតត្រូវជាប់ពន្ធនាគាររបស់រដ្ឋនោះ ប្រសិនបើទណ្ឌិតមាន សិទ្ធទទួលបានការលើកលែងទោស ឬអនុគ្រោះទោស,រដ្ឋសាម៉ីត្រូវជូនដំណឹងទៅតុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ។ ការលើកលែងឬអនុគ្រោះទោសអាចធ្វើបាន ប្រសិនបើប្រធានតុលាការអន្តរជាតិសំរាប់ រ៉្វាន់ដា ធ្វើការ សំរេចថាលើកលែងឬអនុគ្រោះទោស បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយចៅក្រម ហើយដោយផ្អែកលើផលប្រយោជន៍យុត្តិធម៌និងគោលការណ៍ ច្បាប់ទូទៅ ។

## មាត្រា ២៨ ៖ កិច្ចសហប្រតិបត្តិការ និង ជំនួយតុលាការ

១-រដ្ឋទាំងឡាយត្រូវសហការជាមួយតុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ក្នុងកិច្ចការស៊ើបការអង្កេត និង កាត់ទោស ជនណាដែលត្រូវចោទប្រកាន់ពីការប្រព្រឹត្តប្រឆាំងច្បាប់មនុស្សធម៌អន្តរជាតិយ៉ាងធ្ងន់ធរ ។

២-រដ្ឋទាំងឡាយត្រូវអនុវត្ត ដោយមិនអូសបន្លាយពេលវេលា តាមការស្នើសុំជំនួយ ឬបទបញ្ជាដែលចេញ ដោយ សភាជំនុំជម្រះ, ក៏ប៉ុន្តែរួមទាំង មិនត្រូវបានដាក់កំហិតៈ

(ក) អត្តសញ្ញាណ និងទីតាំងរបស់បុគ្គល ។

(ខ) ការប្រមូលចំលើយស្រាយបំភ្លឺរបស់សាក្សី និងភស្តុតាង ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

(គ) ការផ្តល់ឯកសារ ។

(ឃ) ការចាប់ខ្លួន និងឃុំខ្លួនជនជាប់ចោទ ។

(ង) ការប្រគល់ និងបញ្ជូនជនជាប់ចោទអោយតុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា។

## មាត្រា ២៩៖ ឋានៈ បុព្វសិទ្ធិ និង អភ័យឯកសិទ្ធិនៃតុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា

១-អនុសញ្ញាស្តីពីបុព្វសិទ្ធិនិងអភ័យឯកសិទ្ធនៃអង្គការសហប្រជាជាតិ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៤៦ ត្រូវអនុវត្តចំពោះតុលាការអន្តរជាតិសំរាប់ រ៉្វាន់ដា ចៅក្រម ព្រះរាជអាជ្ញា និង បុគ្គលិករបស់គាត់ ក្រឡាបញ្ជីកាន់កាប់បញ្ជីសំណុំរឿង និងបុគ្គលិករបស់គាត់ ។

២-ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជីកាន់កាប់បញ្ជីសំណុំរឿង ត្រូវមាន បុព្វសិទ្ធិនិង អភ័យឯកសិទ្ធិទាំងអស់ការរួចពន្ធ និង បបនភ័ណ្ឌ ដូចដែលផ្តល់ជូនដល់ភ្នាក់ងារការទូត ដោយ អនុលោមតាមច្បាប់អន្តរជាតិ ។

៣-បុគ្គលិករបស់ព្រះរាជអាជ្ញា ក្រឡាបញ្ជីកាន់កាប់បញ្ជីសំណុំរឿង ត្រូវមានបុព្វសិទ្ធិនិង អភ័យឯកសិទ្ធិ ដូចដែល ផ្តល់ជូនដល់មន្ត្រីអង្គការសហប្រជាជាតិដែរ ដោយអនុលោមតាមមាត្រា ៥ និង ៧នៃអនុសញ្ញា យោងតាមកថាខ័ណ្ឌ ១នៃមាត្រានេះ ។

៤-បុគ្គលផ្សេងទៀត រួមបញ្ចូលទាំងជនជាប់ចោទដែលតម្រូវអោយមានវត្តមាននៅទីកន្លែង សវនាការ ឬកន្លែងប្រជុំ របស់តុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ត្រូវបានគេផ្តល់ការ អនុញ្ញាតិ ប្រព្រឹត្តិកម្មបែបនេះគឺជាការចាំបាច់ សំរាប់ការប្រព្រឹត្តិទៅដ៏ត្រឹមត្រូវ នៃតុលាការ អន្តរជាតិ សំរាប់ប្រទេស រ៉្វាន់ដា ។

## មាត្រា ៣០ ៖ ការចំណាយរបស់តុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា

ការចំណាយរបស់តុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា គឺជាការចំណាយរបស់អង្គការ ដោយអនុលោមតាមមាត្រា ១៧ របស់ធម្មនុញ្ញអង្គការសហប្រជាជាតិ ។

## មាត្រា ៣១ ៖ ភាសាផ្លូវការ

ភាសាផ្លូវការរបស់តុលាការអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដាគឺភាសា អង់គ្លេស និងបារាំង ។

## មាត្រា ៣២ ៖ របាយការណ៍ប្រចាំឆ្នាំ


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ប្រធានតុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ត្រូវបញ្ជូនរបាយការណ៍ប្រចាំឆ្នាំរបស់តុលាការអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា ទៅក្រុមប្រឹក្សាសន្តិសុខ និងមហាសន្និបាតរបស់អង្គការសហប្រជាជាតិ។

ប្រភព៖

បកប្រែ៖

វាយឡើងវិញ៖ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលសំរាប់រៀបចំកាត់សេចក្តីមេដឹកនាំខ្មែរក្រហម


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល